**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..១៣៤....សហវ.ប្រ.ក.

# ប្រកាសអន្តរក្រសួង
## ស្តីពី
## បែបបទ និងនីតិវិធីនៃការបង់ភាគលាភកិច្ចហិរញ្ញវត្ថុមិនមែនសារពើពន្ធ សម្រាប់ការនាំចេញផលិតផលរ៉ែ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃ ទី១៨ ខែ សីហា ឆ្នាំ ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១០/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៩ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់វិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រងការនាំចេញផលិតផលរ៉ែ

## សម្រេច

**ប្រការ ១.-**

ប្រកាសអន្តរក្រសួងនេះ កំណត់អំពីបែបបទ និងនីតិវិធីនៃការបង់កាតព្វកិច្ចហិរញ្ញវត្ថុមិនមែនសារពើពន្ធសម្រាប់ការនាំចេញផលិតផលរ៉ែ ដើម្បីធានាការប្រមូលចំណូលប្រកបដោយតម្លាភាព ប្រសិទ្ធភាព បញ្ចៀសការកើតមានបំណុលជាយថាហេតុ និងជួយសម្រួលរំហូរសាច់ប្រាក់របស់អ្នកនាំចេញផលិតផលរ៉ែ។

**ប្រការ ២.-**

ប្រកាសអន្តរក្រសួងនេះ មានវិសាលភាពអនុវត្តចំពោះរាល់ការនាំចេញផលិតផលរ៉ែ ដែលទទួលបានការអនុញ្ញាតឱ្យនាំចេញ អនុលោមតាមនីតិវិធី និងបែបបទសម្រាប់ការស្នើសុំនាំចេញផលិតផលរ៉ែ ដូចមានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ ៣.-**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងប្រកាសអន្តរក្រសួងនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម ៖

- ប្រាក់តម្កល់ធានាកាតព្វកិច្ចហិរញ្ញវត្ថុមិនមែនសារពើពន្ធ ឬប្រាក់តម្កល់អប្បបរមា ៖ សំដៅដល់សមតុល្យទឹកប្រាក់អប្បបរមា សម្រាប់ធានាការអនុវត្តកាតព្វកិច្ចហិរញ្ញវត្ថុមិនមែនសារពើពន្ធរបស់អ្នកនាំចេញផលិតផលរ៉ែ
- ប្រាក់ធានាកាត់កង ៖ សំដៅដល់ប្រាក់ដែលអ្នកនាំចេញផលិតផលរ៉ែ ត្រូវបង់បន្ថែមលើប្រាក់តម្កល់អប្បបរមា សម្រាប់ធានាការកាត់កងកាតព្វកិច្ចហិរញ្ញវត្ថុមិនមែនសារពើពន្ធលើបរិមាណផលិតផលរ៉ែ ដែលបាននាំចេញជាក់ស្តែង

- កាតព្វកិច្ចហិរញ្ញវត្ថុមិនមែនសារពើពន្ធ ៖ សំដៅដល់កាតព្វកិច្ចជាហិរញ្ញវត្ថុ ដែលអ្នកនាំចេញផលិតផលរ៉ែត្រូវបង់ជូនរដ្ឋជាអាទិ៍ សួយសារលើតម្លៃផលិតផលរ៉ែដែលនាំចេញ មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន និងមូលនិធិដទៃទៀត ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ កាតព្វកិច្ចហិរញ្ញវត្ថុមិនមែនសារពើពន្ធនេះ អាចកែប្រែ ឬកំណត់បន្ថែម តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អ្នកនាំចេញផលិតផលរ៉ែ ឬអ្នកនាំចេញ ៖ សំដៅដល់បុគ្គល ដែលទទួលបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ក្នុងការនាំចេញផលិតផលរ៉ែ អនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ ៤.-**

មុនពេលនាំចេញផលិតផលរ៉ែ អ្នកនាំចេញត្រូវបង់ ៖

១. ប្រាក់តម្កល់អប្បបរមាចំនួន ៥% (ប្រាំភាគរយ) នៃថ្លៃសួយសារលើផលិតផលរ៉ែនាំចេញតាមបរិមាណគោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញនីមួយៗ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២. ប្រាក់ធានាកាត់កង សម្រាប់ការកាត់កងកាតព្វកិច្ចហិរញ្ញវត្ថុមិនមែនសារពើពន្ធ តាមការនាំចេញជាក់ស្តែង។

ក្រសួងរ៉ែ និងថាមពល ត្រូវបញ្ឈប់ការផ្តល់វិញ្ញាបនបត្របញ្ជាក់ការនាំចេញ ឬស្នើសុំកិច្ចសហការជាមួយស្ថាប័នមានសមត្ថកិច្ចដទៃទៀត ដើម្បីបញ្ឈប់ការនាំចេញជាបណ្តោះអាសន្ន ក្នុងករណីដែលសមតុល្យនៃប្រាក់ធានាកាត់កងទាបជាងកាតព្វកិច្ចហិរញ្ញវត្ថុមិនមែនសារពើពន្ធ ដែលត្រូវទូទាត់ទៅលើបរិមាណផលិតផលរ៉ែផ្អែកតាមវិញ្ញាបនបត្របញ្ជាក់ការនាំចេញដែលស្នើសុំ ឬទាបជាងកាតព្វកិច្ចហិរញ្ញវត្ថុមិនមែនសារពើពន្ធ ដែលត្រូវទូទាត់បរិមាណផលិតផលរ៉ែនាំចេញជាក់ស្តែង។

**ប្រការ ៥.-**

អ្នកនាំចេញ ត្រូវបង់ប្រាក់តម្កល់អប្បបរមា និងប្រាក់ធានាកាត់កង ស្របតាមប្រការ ៤ នៃប្រកាសនេះ ក្រោយពីទទួលបានលិខិតបញ្ជាបង់ប្រាក់ពីក្រសួងរ៉ែ និងថាមពល។

អ្នកនាំចេញ ត្រូវបង់ប្រាក់តម្កល់អប្បបរមា និងប្រាក់ធានាកាត់កងយ៉ាងតិច ៥ (ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការមុនពេលនាំចេញផលិតផលរ៉ែលើកដំបូង។

ប្រាក់តម្កល់អប្បបរមា ត្រូវបង់ចូលគណនីនៅធនាគារពាណិជ្ជដៃគូ ដែលមានម្ចាស់គណនីជាតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ក្រុមការងារទារបំណុលអន្តរក្រសួង) និងក្រសួងរ៉ែ និងថាមពល។

ប្រាក់ធានាកាត់កង ត្រូវបង់ចូលគណនីនៅធនាគារពាណិជ្ជដៃគូតាមការកំណត់ក្នុងលិខិតបញ្ជាបង់ប្រាក់

ដោយមានបញ្ជាក់ច្បាស់លាស់ អំពីយថាប្រភេទផលិតផលរ៉ែ យថាប្រភេទខ្ទង់ចំណូល និងកាលបរិច្ឆេទបង់ប្រាក់។ គណនីសម្រាប់ដាក់ប្រាក់ធានាកាត់កងនេះ ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បន្ទាប់ពីបានបង់ប្រាក់តម្កល់អប្បបរមា និងប្រាក់ធានាកាត់កងរួច អ្នកនាំចេញ ត្រូវផ្តល់សក្ខីបត្របញ្ជាក់ការបង់ប្រាក់នៅធនាគារពាណិជ្ជដែលគួជូនក្រសួងរ៉ែ និងថាមពល (អគ្គនាយកដ្ឋានធនធានរ៉ែ) ចំនួន ០១ (មួយ) ច្បាប់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក្រុមការងារទារបំណុលអន្តរក្រសួង) ចំនួន ០១ (មួយ) ច្បាប់ ជាឯកសាររឹង ឬទន់ តាមរយៈមន្ត្រីទទួលបន្ទុក ឬបណ្តាញទំនាក់ទំនងសង្គមតេឡេក្រាម ឬតាមមធ្យោបាយសមស្របណាមួយ។

**ប្រការ ៦.-**

អ្នកនាំចេញត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងរ៉ែ និងថាមពល និងចម្លងជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក្រុមការងារទារបំណុលអន្តរក្រសួង) នៅរៀងរាល់សប្តាហ៍ទី ០១ នៃខែបន្ទាប់ ដោយភ្ជាប់មកជាមួយនូវសក្ខីបត្របញ្ជាក់ការបង់ប្រាក់ដែលបាននាំចេញកន្លងមក និងប្រតិវេទន៍គយ ដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់។

**ប្រការ ៧.-**

ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក្រុមការងារទារបំណុលអន្តរក្រសួង) ត្រូវសហការចាត់ចែងឱ្យមានយន្តការតាមដាន កត់ត្រា និងពិនិត្យការកាត់កងកាតព្វកិច្ចហិរញ្ញវត្ថុមិនមែនសារពើពន្ធជាប្រចាំ។

ផ្អែកតាមសំណើសុំនាំចេញដំបូងរបស់អ្នកនាំចេញ ក្រសួងរ៉ែ និងថាមពល ត្រូវជូនដំណឹងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្នុងករណីចាំបាច់ ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំក្រុមការងារអន្តរក្រសួង ដើម្បីតាមដាន កត់ត្រា និងពិនិត្យការកាត់កងកាតព្វកិច្ចហិរញ្ញវត្ថុមិនមែនសារពើពន្ធ។

**ប្រការ ៨.-**

អ្នកនាំចេញ ត្រូវដាក់ពាក្យស្នើសុំមកក្រសួងរ៉ែ និងថាមពល ដើម្បីដកប្រាក់តម្កល់អប្បបរមា ក្រោយបញ្ចប់ការនាំចេញជាស្ថាពរ និងក្នុងលក្ខខណ្ឌ ដែលអ្នកនាំចេញផលិតផលរ៉ែបានបំពេញកាតព្វកិច្ចនានាត្រឹមត្រូវ និងចប់សព្វគ្រប់។

ក្នុងករណីដែលអ្នកនាំចេញបានបំពេញនូវលក្ខខណ្ឌ និងកាតព្វកិច្ចនានាបានត្រឹមត្រូវ និងចប់សព្វគ្រប់រួចរាល់ ក្រសួងរ៉ែ និងថាមពល ត្រូវលើកសំណើសុំការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបង្វែរប្រាក់តម្កល់អប្បបរមាជូនអ្នកនាំចេញវិញ។

**ប្រការ ៩.-**

ប្រាក់តម្កល់អប្បបរមា ត្រូវចាត់ទុកជាគុណប្រយោជន៍ថវិកាជាតិ ក្នុងករណីដែលអ្នកនាំចេញស្ថិតក្នុងស្ថានភាព និងលក្ខខណ្ឌ ដូចខាងក្រោម÷

- មិនបានបំពេញកាតព្វកិច្ចហិរញ្ញវត្ថុមិនមែនសារពើពន្ធ និង/ឬកាតព្វកិច្ចផ្សេងទៀត ដែលមានកំណត់ក្នុងប្រកាសនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន
- ត្រូវបានបិទបញ្ចប់ការនាំចេញជាអចិន្ត្រៃយ៍ពីក្រសួងរ៉ែ និងថាមពល ក្នុងករណីល្មើសច្បាប់
- គោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញ ត្រូវបានដកហូតដោយសារការប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- អាជ្ញាបណ្ណធនធានរ៉ែត្រូវបានដកហូត។

ការរឹបអូសប្រាក់តម្កល់អប្បបរមានេះ មិនអនុញ្ញាតឱ្យអ្នកនាំចេញរួចផុតពីកាតព្វកិច្ចហិរញ្ញវត្ថុ និងទោសទណ្ឌនានាដែលខ្លួនត្រូវទទួលខុសត្រូវ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ ១០.-**

ប្រាក់ធានាកាត់កង ដូចបានកំណត់នៅក្នុងប្រការ ៤ នៃប្រកាសនេះ អ្នកនាំចេញពុំមានសិទ្ធិធ្វើការដកប្រាក់ធានាកាត់កង ដែលនៅសល់វិញបានឡើយ។ ប្រាក់ធានាកាត់កង ដែលនៅសល់អាចធ្វើការបូកយោងសម្រាប់យកទៅទូទាត់ជាមួយនឹងកាតព្វកិច្ចហិរញ្ញវត្ថុមិនមែនសារពើពន្ធ តាមបរិមាណនៃគោលការណ៍កំណត់កូតាអនុញ្ញាតឱ្យនាំចេញផលិតផលរ៉ែបន្ទាប់។

ក្នុងករណីដែលក្រសួងរ៉ែ និងថាមពលបិទបញ្ចប់ការនាំចេញជាអចិន្ត្រៃយ៍ ឬដកហូតអាជ្ញាបណ្ណ ឬបញ្ចប់អាជ្ញាបណ្ណប្រាក់ធានាកាត់កងដែលនៅសល់ ត្រូវចាត់ទុកជាគុណប្រយោជន៍ថវិកាជាតិ។

**ប្រការ ១១.-**

បែបបទ នីតិវិធី និងអត្រាសួយសារលើតម្លៃផលិតផលរ៉ែសម្រាប់ការនាំចេញ ត្រូវអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ ១២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៣.-**

អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងរ៉ែ និងថាមពល ព្រមទាំងអ្នកនាំចេញផលិតផលរ៉ែ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១៤.-**

ប្រកាសអន្តរក្រសួងនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២៤ តទៅ។

ថ្ងៃ ពុធ ១២ កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**កែវ រតនៈ**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្ត
- គ្រប់មន្ទីររ៉ែ និងថាមពល រាជធានី ខេត្ត
- ដូចប្រការ ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ